**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១១៥ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារសម្របសម្រួលការត្រៀមរៀបចំ ឆ្លើយតប សង្គ្រោះបន្ទាន់ និងស្តារឡើងវិញរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/២៣៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៤ ស្តីពីការកែតម្រូវមាត្រា១ និងមាត្រា២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២
- បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០០២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- យោងតាមសំណើរបស់ទេសរដ្ឋមន្ត្រីទទួលបន្ទុកជាអនុប្រធានទី១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារសម្របសម្រួលការត្រៀមរៀបចំ ឆ្លើយតបសង្គ្រោះបន្ទាន់ និងការស្តារឡើងវិញ របស់គណៈ កម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម) ដែលមានសមាសភាពដូចខាងក្រោមៈ

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម | ញឹម វណ្ណដា | ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានទី១ គ.ជ.គ.ម | ប្រធាន |
| ២. | ឯកឧត្តម | ម៉ឹង សំផន | រដ្ឋលេខាធិការក្រសួងការពារជាតិ | អនុប្រធាន |
| ៣. | ឯកឧត្តម | តេង សាវង្ស | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |

| | | | | |
|---|---|---|---|---|
| ៤. | ឯកឧត្តម | ហ៊ូ តាំងអេង | រដ្ឋលេខាធិការក្រសួងផែនការ | អនុប្រធាន |
| ៥. | ឯកឧត្តម | ស៊ូ ភិរិន្ទ | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦. | ឯកឧត្តម | លឹម ស៊ីវេនីន | រដ្ឋលេខាធិការក្រសួងសាធារណៈការ និងដឹកជញ្ជូន | សមាជិក |
| ៧. | ឯកឧត្តម | នាយឧត្តមសេនីយ៍ ហ៊ីង ប៊ុនហៀង | មេបញ្ជាការកងឯកភាពអង្គរក្សសម្តេចនាយករដ្ឋមន្ត្រី | សមាជិក |
| ៨. | ឯកឧត្តម | យិន គិមស៊ាន | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៩. | ឯកឧត្តម | អះ ម៉ាត់យ៉ះយ៉ា | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១០. | ឯកឧត្តម | សាក់ ខាន់ | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១១. | ឯកឧត្តម | ឌិម គឹមស៊ា | រដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ | សមាជិក |
| ១២. | ឯកឧត្តម | អ៊ិន ចន្ទា | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៣. | ឯកឧត្តម | តែ គុយស៊ាង | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១៤. | លោកជំទាវ | ស៊ីវណ្ណ បុទុម | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិក |
| ១៥. | ឯកឧត្តម | ណាត ប៊ុនរឿន | រដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា | សមាជិក |
| ១៦. | ឯកឧត្តម | ហ៊ុយ ហានសុង | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៧. | ឯកឧត្តម | ហេង សុខគង់ | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ១៨. | ឯកឧត្តម | ហ៊ី បារី | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានអគ្គនាយកកំពង់ផែស្វយ័តភ្នំពេញ | សមាជិក |
| ១៩. | ឯកឧត្តម | នាយឧត្តមសេនីយ៍ ស៊ឹង សំណាង | មេបញ្ជាការកងទ័ពជើងអាកាស | សមាជិក |
| ២០. | ឯកឧត្តម | លូ គឹមឈុន | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកំពង់ផែស្វយ័តក្រុងព្រះសីហនុ | សមាជិក |
| ២១. | ឯកឧត្តម | នាយឧត្តមសេនីយ៍ យុន ឈុននី | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ២២. | ឯកឧត្តម | ឧត្តមសេនីយ៍ឯក វង្ស ពិសេន | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ២៣. | ឯកឧត្តម | ហង្ស សាមឿន | អនុប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | សមាជិក |
| ២៤. | ឯកឧត្តម | ប៉ុន ណារិទ្ធិ | អគ្គលេខាធិការគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | សមាជិក |
| ២៥. | ឯកឧត្តម | អ៊ុយ សំអាត | តំណាងកាកបាទក្រហមកម្ពុជា | សមាជិក |
| ២៦. | ឯកឧត្តម | ឡាំ ហេងហួត | អគ្គលេខាធិការរងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | សមាជិក |
| ២៧. | ឯកឧត្តម | វង្ស សណ្តាប់ | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ២៨. | ឯកឧត្តម | ឃួន ផុនរតនៈ | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២៩. | ឯកឧត្តម | ហ៊ុយ សាវ៉ុជ | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ៣០. | ឯកឧត្តម | គឹម សុភ័ណ | អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ៣១. | ឯកឧត្តម | កៅ ល្អប្រពៃ | អនុរដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |

| | | | |
|---|---|---|---|
| ៣២.ឯកឧត្តម | ឧត្តមសេនីយ៍ឯក ពៅ ផារី មេបញ្ជាការរង បញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការ | | សមាជិក |
| ៣៣.ឯកឧត្តម | ឧត្តមសេនីយ៍ទោ ម៉ែន សំអន តំណាងអគ្គមេបញ្ជាការ | កងយោធពលខេមរភូមិន្ទ | សមាជិក |
| ៣៤.ឯកឧត្តម | ធន វិរៈ | អគ្គនាយករងក្រសួងពាណិជ្ជកម្ម ទទួលបន្ទុកជាអគ្គនាយកក្រុមហ៊ុនហ្រ្វីនគ្រេដ | សមាជិក |
| ៣៥.ឯកឧត្តម | ឆាន់ សូរ្យផល | អគ្គនាយកសំណង់ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៣៦.ឯកឧត្តម | នាង ឆែន | ប្រធាននាយកដ្ឋានឆ្លើយតប សង្គ្រោះបន្ទាន់ និងស្តារឡើងវិញ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | សមាជិក |
| ៣៧.លោក | ម៉ៅ ហាក់ | អគ្គនាយករងកិច្ចការបច្ចេកទេស និងជាប្រធាននាយកដ្ឋានជលសាស្ត្រ និងការងារទន្លេនៃក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៣៨.លោក | សំ ពៅ | អនុប្រធាននាយកដ្ឋានឆ្លើយតប សង្គ្រោះបន្ទាន់ និងស្តារឡើងវិញ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | សមាជិក |

**ប្រការ២ .-**

ក្រុមការងារសម្របសម្រួលការត្រៀមរៀបចំ ឆ្លើយតបសង្គ្រោះបន្ទាន់ និងស្តារឡើងវិញ មានទីប្រឹក្សាដែលជាអ្នកសម្របសម្រួលសហប្រជាជាតិ (UNRC) និងជាប្រធានតំណាងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ប្រចាំនៅកម្ពុជាចូលរួម។

**ប្រការ៣ .-**

ក្រុមការងារនេះមានភារកិច្ចដូចតទៅ៖

- សម្របសម្រួលលើការដឹកនាំ និងសហការជាមួយក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ភាគីបាទក្រហមកម្ពុជា អ្នកសម្របសម្រួលសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ អង្គការជាតិ-អន្តរជាតិ រៀបចំ និងដាក់ចេញនូវផែនការត្រៀមរៀបចំ ឆ្លើយតបសង្គ្រោះបន្ទាន់ និងស្តារឡើងវិញ នៅពេលមានគ្រោះមហន្តរាយ។
- កៀរគរគ្រឿងបរិក្ខារ មូលដ្ឋានសម្ភារៈ មធ្យោបាយ ធនធានមនុស្ស និងហិរញ្ញវត្ថុ និងទទួលយកមូលនិធិជាវិភាគទានស្ម័គ្រចិត្ត ឬអំណោយស្ម័គ្រចិត្តពីអង្គការជាតិ-អន្តរជាតិ និងសប្បុរសជនក្នុងប្រទេស និងក្រៅប្រទេស សម្រាប់ការឆ្លើយតប សង្គ្រោះបន្ទាន់ និងស្តារឡើងវិញ នៅពេលមានគ្រោះមហន្តរាយ។
- ផ្សព្វផ្សាយសភាពការណ៍គ្រោះមហន្តរាយ និងទទួលយកព័ត៌មានពីខ្សែបណ្តាយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (អាជ្ញាធររាជធានីខេត្ត ស្រុក ក្រុង ខណ្ឌ ឃុំ សង្កាត់) និងក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល និងតំបន់ ដើម្បីចងក្រងជាផែនការឆ្លើយតបគ្រោះមហន្តរាយ ។
- រៀងរាល់ឆ្នាំក្រុមការងារ ធ្វើការប្រជុំវាយតម្លៃ និងប៉ាន់ប្រមាណការប៉ះពាល់ ខូចខាត បាត់បង់ និងតាមដានត្រួតពិនិត្យ ការឆ្លើយតបសង្គ្រោះបន្ទាន់ និងការស្តារឡើងវិញ ដើម្បីរាយការណ៍ជូនទីស្តីការគណៈរដ្ឋមន្ត្រី និងប្រមុខរាជរដ្ឋាភិបាល។
- ត្រូវធ្វើការប្រជុំ១ខែម្តងតាមការកោះអញ្ជើញរបស់ប្រធាន ឬក្នុងករណីចាំបាច់ត្រូវធ្វើការប្រជុំវិសាមញ្ញ ដើម្បីដកបទពិសោធន៍ទៅតាមស្ថានភាពជាក់ស្តែង។

**ប្រការ៤.-**

ប្រធានក្រុមការងារមានសិទ្ធិបង្កើតអនុក្រុមតាមផ្នែកជំនាញនីមួយៗ និងក្រុមលេខា ដើម្បីជួយការងារតាមតួនាទីជាក់ស្តែង ដោយមានមន្ត្រីជំនាញ ក្រសួង-ស្ថាប័នពាក់ព័ន្ធ តំណាងភ្នាក់ងារសហប្រជាជាតិ ដៃគូអភិវឌ្ឍន៍ អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ចូលរួម។

**ប្រការ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកជាអនុប្រធានទី ១ គជគម**

**ញឹម វណ្ណដា**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ